**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

# ញត្តិគាំទ្រ

ថ្នាក់ដឹកនាំ នាយទាហាន នាយទាហានរង និងពលទាហានក្រសួងការពារជាតិ សូមប្រកាសគាំទ្រយ៉ាងពេញទំហឹង ចំពោះសារសម្លេងពិសេសរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** បានថ្លែងនារសៀលថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៤ ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការអភិវឌ្ឍតំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម។ ក្រសួងការពារជាតិ សូមថ្កោលទោស ចំពោះក្រុមប្រឆាំងជ្រុលនិយមមួយក្តាប់តូចនៅក្រៅប្រទេស បាននិងកំពុងធ្វើសកម្មភាពអំពាវនាវ និងបំផុសបំផុល ញុះញង់ ឱ្យប្រជាពលរដ្ឋ និងកងកម្លាំងប្រដាប់អាវុធ ធ្វើការបះបោរផ្តួលរំលំប្រឆាំងនឹងរាជរដ្ឋាភិបាលស្របច្បាប់នៅកម្ពុជា។

កងយោធពលខេមរភូមិន្ទ នៅតែជាឆ្អឹងខ្នងដ៏រឹងមាំបំផុតរបស់រាជរដ្ឋាភិបាល ការពារដាច់ខាតរាជរដ្ឋាភិបាលស្របច្បាប់ ដែលកើតចេញពីការបោះឆ្នោតដោយប្រជាពលរដ្ឋ ដូចនេះ ការប៉ុនប៉ងអូសទាញ ប្រទេសកម្ពុជាឱ្យធ្លាក់ក្នុងសភាពវឹកវរ ហឹង្សា បង្ហូរឈាម និងឈានទៅរកសង្គ្រាមស៊ីវិលសារជាថ្មី គឺជាអំពើល្មើសច្បាប់មិនអាចអត់ឱនបានឡើយ។ ហេតុនេះ ក្រសួងការពារជាតិ សូមប្រឆាំងដាច់ខាតរាល់ឧបាយកល សកម្មភាពនៃការប៉ុនប៉ងការផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ ផ្ទុយពីគោលការណ៍លទ្ធិប្រជាធិបតេយ្យ។

ក្រសួងការពារជាតិ សូមប្រកាសជាឱឡារិកស្មោះត្រង់ដោយឥតងាករេ និងគាំទ្រយ៉ាងពេញទំហឹងចំពោះរាជរដ្ឋាភិបាលកម្ពុជា ដឹកនាំដោយ**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** និងប្តេជ្ញាការពារឱ្យបានជាដាច់ខាតនូវសុខសន្តិភាព ស្ថេរភាពនយោបាយ អធិបតេយ្យភាពជាតិ និងបូរណភាពទឹកដី ទោះជាក្នុងតម្លៃណាក៏ដោយ។

ថ្ងៃអង្គារ ៩កើតខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២៤